00824942

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 20 / 07 / 2012
ម៉ោង (Time/Heure): 10:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E204/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២

**ជូនចំពោះ:** ភាគីនៃសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** ចម្លើយតបទៅនឹងសំណើរបស់ជនជាប់ចោទ នួន ជា សុំឲ្យមានការបង្ហាញដីកាបញ្ជូនរឿងទៅពិនិត្យក្នុងសំណុំរឿង ០០៣ (ឯកសារ E204)

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយរបស់មេធាវីការពារជនជាប់ចោទ នួន ជា ស្នើសុំឲ្យអង្គជំនុំជម្រះបង្គាប់ឲ្យសហព្រះរាជអាជ្ញាបង្ហាញ "ដីកាបញ្ជូនរឿងទៅពិនិត្យក្នុងសំណុំរឿង ០០៣" និងដាក់ឯកសារនេះក្នុងសំណុំរឿង ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ។ មេធាវីការពារជនជាប់ចោទ នួន ជា ក៏បានលើកឡើងជាថ្មីនូវសំណើរបស់ខ្លួនដែលស្នើសុំអង្គជំនុំជម្រះសាលាដំបូងកំណត់កាលបរិច្ឆេទនៃការផ្តល់សក្ខីកម្មរបស់បុគ្គលនានាក្នុងសំណុំរឿង ០០២។ សហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងសំណើខាងលើនេះ កាលពីថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២ (ឯកសារ E204/1)។

២. នាពេលបច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងពុំបានទទួលសំណុំរឿងណាមួយផ្សេងទៀតក្រៅពីសំណុំរឿង ០០២ ឡើយ ទើបបានជាអង្គជំនុំជម្រះពុំអាចពិនិត្យមើលឯកសារសម្ងាត់ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ

E204/2

ណាមួយដែលកំពុងប្រព្រឹត្តទៅ។ មានតែសហចៅក្រមស៊ើបអង្កេតប៉ុណ្ណោះដែលមានសិទ្ធិតាមផ្លូវច្បាប់ ក្នុងការដាក់ចំណាត់ថ្នាក់ឡើងវិញទៅលើឯកសារនៃកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ ដែលជាឯកសារសម្ងាត់ ឬអនុញ្ញាតឱ្យបុគ្គលទាំងឡាយដែលពុំមែនជាភាគីនៃកិច្ចស៊ើបសួរអាចពិនិត្យមើលឯកសារទាំងនោះបាន (*សូមមើល* វិធាន ៥៦(២) នៃវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីអំពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង)។ ហេតុដូច្នេះ អង្គជំនុំជម្រះពុំមានសិទ្ធិដើម្បីទទួលយកសំណើសុំនេះឡើយ។

៣. ទោះយ៉ាងណា មេធាវីការពារជនជាប់ចោទ នួន ជា ពុំបញ្ជាក់អំពីមូលដ្ឋាននៃសំណើរបស់ខ្លួនឡើយ ប៉ុន្តែបានត្រឹមតែលើកឡើងអំពីសិទ្ធិរបស់ជនជាប់ចោទ នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និង "ស្មារតីនៃភាពយុត្តិធម៌ និងសមភាពនៃមធ្យោបាយក្នុងការតទល់ក្តី" ជាទូទៅប៉ុណ្ណោះ (ឯកសារ E204)។ ថ្វីដ្បិតសហព្រះរាជអាជ្ញាអាចមានតួនាទីជាភាគីនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ និងកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ (និងមានសិទ្ធិពិនិត្យមើលឯកសារសម្ងាត់ ដែលភាគីដទៃក្នុងសំណុំរឿង០០២ ឬអង្គជំនុំជម្រះពុំអាចពិនិត្យមើលបាន) ក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថាប្រការនេះមិនរំលោភលើគោលការណ៍សមភាពនៃមធ្យោបាយក្នុងការតទល់ក្តីឡើយ។ ស្ថានភាពបែបនេះកើតមានដោយសាររចនាសម្ព័ន្ធនៃ អ.វ.ត.ក និងកើតមានជាធម្មតាជាមួយសមត្ថកិច្ចរបស់ព្រះរាជអាជ្ញាជាតិទាំងនៅក្នុងយុត្តាធិការច្បាប់ស៊ីវិលឡូ (civil law) និងច្បាប់ខមិនឡូ (common law)។ ជាងនេះទៅទៀត នៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញា សហព្រះរាជអាជ្ញាបានធ្វើការគូសបញ្ជាក់ថាខ្លួនដឹងអំពីកាតព្វកិច្ចរបស់ខ្លួនក្នុងការបង្ហាញឯកសារណាមួយដែលខ្លួនមាន ដែលអាចបង្ហាញអំពីភាពគ្មានទោស ឬការដោះបន្ទុកដល់ជនជាប់ចោទណាម្នាក់ក្នុងសំណុំរឿង ០០២ ប៉ុន្តែសហព្រះរាជអាជ្ញាបានធ្វើការកត់សម្គាល់យ៉ាងត្រឹមត្រូវថាសំណើរបស់ជនជាប់ចោទ នួន ជា ពុំបានចោទប្រកាន់ ឬព្យាយាមតាមវិធីណាមួយដើម្បីបង្ហាញថាឯកសារដែលខ្លួនបានស្នើសុំនោះ ពាក់ព័ន្ធនឹងសំណុំរឿងប្រឆាំងនឹងជនជាប់ចោទ នួន ជា ឡើយ។ ជំនួសមកវិញ សំណើសុំខាងលើហាក់ដូចជាការជំរុញនៃយុទ្ធសាស្ត្ររបស់មេធាវីការពារជនជាប់ចោទ នួន ជា ក្នុងការលើកបញ្ហាដែលពុំពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ដែលអង្គជំនុំជម្រះធ្លាប់បានធ្វើអត្ថាធិប្បាយរួចមកហើយ ( ឯកសារ E214, ទំព័រ ១០)។

E204/2

៤. តបទៅនឹងសំណើសុំកំណត់កាលបរិច្ឆេទនៃការផ្តល់សក្ខីកម្មរបស់សាក្សីនានា អង្គជំនុំជម្រះកត់សម្គាល់ឃើញថាមេធាវីការពារជនជាប់ចោទ នួន ជា បានស្នើអង្គជំនុំជម្រះស្តាប់សក្ខីកម្មរបស់សាក្សីចំនួនច្រើនជាង ៥០០ នាក់ក្នុងសំណុំរឿង ០០២ (ឯកសារ E9/4/4.4)។ អង្គជំនុំជម្រះសូមបញ្ជាក់ថា ដើម្បីធានាបាននូវការជំនុំជម្រះដោយយុត្តិធម៌ និងឆាប់រហ័ស អង្គជំនុំជម្រះពុំអាចស្តាប់សក្ខីកម្មរបស់សាក្សីទាំងអស់បានទេ។ អង្គជំនុំជម្រះធ្លាប់បានបង្ហាញអត្តសញ្ញាណសាក្សីដែលខ្លួនយល់ថាជាសាក្សីដែលពាក់ព័ន្ធបំផុតទៅនឹងកម្មវត្ថុនៃសំណុំរឿង ០០២/០១ (ឯកសារ E131/1.1) និងបានបញ្ជាក់បំភ្លឺថា សេចក្តីសម្រេចស្តីពីសាក្សីផ្សេងៗដែលភាគីបានស្នើសុំកោះហៅនឹងមាននៅពេលសមស្រប (*សូមមើលជាឧទាហរណ៍* ឯកសារ E131/1.1, ឯកសារ E172)។

៥. នេះគឺជាចម្លើយជាផ្លូវការរបស់អង្គជំនុំជម្រះតបទៅនឹងសំណើ E204។